CAMBODIAN (KHMER)

ក្រសួងនគរបាលស៊ីអាត្តិល

# ការប្រើលេខ 9-1-1

## សំរាប់កិច្ចការអ្នកបកប្រែ

### ហៅលេខ 9-1-1 នៅពេល ៖

■ អ្នកត្រូវការប៉ូលិស អ្នកពន្លត់ភ្លើង ឬមានបញ្ហាសុខភាពជាអាសន្ន ។

■ ដើម្បីរាយការណ៍បទឧក្រិដ្ឋ ដែលកំពុងតែកើតឡើង ឬទើបបានកើត ឡើងថ្មីៗ ។

■ មានស្ថានការណ៍ដែលអាច ឬនាំឲ្យគ្រោះថ្នាក់ដល់ជីវិត ឬទ្រព្យសម្បត្តិ ឬទាំងពីរមុខ ។

■ មានការសង្ស័យទៅលើសកម្មភាពអ្វីជាប់ទាក់ទងមនុស្ស ឬរថយន្ត ដែលទំនងជាឧក្រិដ្ឋកម្មដោយមានចេតនា ។

ប្រព័ន្ធលេខ 9-1-1 មានអ្នកបកប្រែដើម្បីជួយអ្នក បើសិនជាអ្នកចេះភាសាអង់គ្លេសតិចតួច ឬមិនចេះសោះ ។

1. កាលណាអ្នកហៅ ជាដំបូងបំផុត ត្រូវថ្លែងប្រាប់ជាភាសាអង់គ្លេសពីការបំរើដែលអ្នកត្រូវការ ហើយអ្នកនិយាយភាសាអ្វី ។



"I need POLICE. I speak CAMBODIAN."
"ខ្ញុំត្រូវការប៉ូលិស ។ ខ្ញុំនិយាយភាសាខ្មែរ" ។



"I need the FIRE DEPARTMENT. I speak CAMBODIAN."
"ខ្ញុំត្រូវការក្រសួងអគ្គិភ័យ ។ ខ្ញុំនិយាយភាសាខ្មែរ" ។



"I need MEDICAL help. I speak CAMBODIAN."
"ខ្ញុំត្រូវការជំនួយពីពេទ្យ ។ ខ្ញុំនិយាយភាសាខ្មែរ" ។

2. អ្នកចាំទទួលទូរស័ព្ទលេខ 9-1-1 នឹងតភ្ជាប់អ្នកជាមួយអ្នកបកប្រែម្នាក់ក្នុងរយៈពេលដ៏ខ្លី ។ ត្រូវនៅកាន់ស្តាប់ទូរស័ព្ទក្នុងពេលតភ្ជាប់ ។

3. កាលណាអ្នកបកប្រែចូលមក ត្រូវឆ្លើយសំណួរដែលគេសួរអ្នក ។ សូមប្រាប់គេពីការអ្វីបានកើតឡើងពិតៗ ដោយត្រួសៗបំផុត ។

CAMBODIAN (KHMER)

# ក្រសួងនគរបាលស៊ីអាត្លិល

## ការប្រើលេខ 9-1-1 សំរាប់កិច្ចការអ្នកបកប្រែ

4. អ្នកចាំទទួលទូរស័ព្ទលេខ 9-1-1 សំរេចពីរបៀបជួយអ្នកយ៉ាងល្អ ចេញពីពត៌មានដែលអ្នកបានផ្តល់ ។ ត្រូវត្រៀមខ្លួនជាស្រេច ដើម្បីប្រាប់អ្នកចាំទទួលទូរស័ព្ទ :

- ■ ទីកន្លែងនៃភាពអាសន្នដែលកំពុងកើតហេតុ ។ គឺរួមមានលេខអាគារ លេខផ្ទះឬបន្ទប់ ឈ្មោះផ្លូវ និងពត៌មានអ្វីមួយដែលប្រាប់ទិសដៅ (ដូចជា ខាងជើងឆៀងខាងលិច ឬខាងត្បូង ជាដើម)

- ■ ឈ្មោះរបស់អ្នក ឬអាសយដ្ឋាន និងលេខទូរស័ព្ទ ដែលអ្នកកំពុងតែហៅឲ្យជួយ ។

5. ចូរកុំដាក់ទូរស័ព្ទចុះឲ្យសោះ រហូតទាល់តែគេបានបង្គាប់អ្នក ។ ត្រូវនៅកាន់ស្តាប់ទូរស័ព្ទ រហូតទាល់តែអ្នកចាំទទួលទូរស័ព្ទប្រាប់អ្នកឲ្យដាក់ចុះ ។

បើសិនជាអ្នកត្រូវការអ្នកបកប្រែ ឲ្យនិយាយទាក់ទងជាមួយប៉ូលិស បន្ទាប់ពីប៉ូលិសបានមកដល់ នោះយើងអាចផ្តល់ជូនអ្នកបាន ។

## សូមកំណត់ :

- ■ ការហៅលេខ 9-1-1 ចេញពីទូរស័ព្ទដាក់កាក់ គឺឥតបង់ថ្លៃឡើយ ។

- ■ បើសិនជាអ្នកមិនចង់ប្រាប់ឈ្មោះឲ្យគេដឹង ឬចង់រក្សាពត៌មានជាសំងាត់ សូមប្រាប់អ្នកចាំទទួលទូរស័ព្ទ ។

- ■ បើសិនជាអ្នកបានហៅលេខ 9-1-1 ដោយចៃដន្យ ចូរកុំដាក់ចុះឲ្យសោះ! ត្រូវនៅកាន់ស្តាប់ទូរស័ព្ទ ហើយប្រាប់គេថាអ្នកគ្មានបំណងទូរស័ព្ទមកទេ ។

បានផលិតដោយក្រសួងនគរបាលស៊ីអាត្លិល (2005) ដោយរួមសហការជាមួយក្រុមភូមិឋានស៊ីអាត្លិល ។

www.seattle.gov/police

610 Fifth Avenue
P.O. Box 34986
Seattle, WA 98123-4986

Seattle Neighborhood Group
www.sngi.org

1806 East Yesler Way
Seattle, WA 98122-5748